ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ: 039/16 អ.ល.គ

# របាយការណ៍បូកសរុបសកម្មភាព
# និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមករា និងទិសដៅខែ កុម្ភៈ ឆ្នាំ ២០១៦

( គិតចាប់ពីថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៥ ដល់ថ្ងៃទី ២៥ ខែមករា ឆ្នាំ២០១៦ )

## I.ស្ថានភាពទូទៅ

អំពើជួញដូរមនុស្សដែលចាត់ទុកថា ជាទាសភាពសម័យទំនើប គឺជាបញ្ហាសកលដែលកំពុងតែជះឥទ្ធិពលលើប្រទេសជាច្រើន នៅក្នុងពិភពលោក រួមទាំងប្រទេសកម្ពុជាផងដែរ បាតុភូតជាប្រវត្តិសាស្ត្រនេះ បានវិវឌ្ឍន៍ និងផ្លាស់ប្តូររូបភាព អាស្រ័យទៅតាមស្ថានភាពសេដ្ឋកិច្ច នយោបាយ និងបរិយាកាសសង្គមដែលទាមទារឲ្យមានការរួបរួមគ្នាប្រយុទ្ធប្រឆាំងបង្ការទប់ស្កាត់អំពើជួញដូរ មនុស្សឲ្យបានទាន់ពេលវេលា ។

សេចក្តីត្រូវការផ្នែកសម្ភារ និងស្មារតី របស់មនុស្សកំពុងអភិវឌ្ឍបណ្តើរៗ ដើម្បីជីវភាពគ្រួសារមួយ ពួកគេរិះរកគ្រប់វិធីទោះបីឆ្លងកាត់ឧបសគ្គ និងហានិភ័យទាំងឡាយ ក៏ពួកគេនៅតែជម្នះធ្វើយ៉ាងណា ដើម្បីសម្រេចតាម គោលបំណងរបស់ ខ្លួនអ្នកខ្លះមានមហិច្ឆតាខ្ពស់ រហូតបង្កើតគំនិតប្រាស់ចាកពីច្បាប់នៅក្នុងសង្គមមនុស្ស បង្កភាពស្មុគស្មាញដល់គ្រួសារ ដល់អ្នកដទៃ ដល់ប្រទេសជាតិ និងនៅជុំវិញពិភពលោក បង្កើតជាបទល្មើសផ្សេងៗ ជាពិសេសអំពើជួញដូរមនុស្ស ហើយពួកជនទាំងនោះធ្វើសកម្មភាពបោកបញ្ឆោតលើជនទន់ខ្សោយ អវិជ្ជា ក្រីក្រ អូសទាញតាមរូប ភាពផ្សេងៗ តាមរយៈរកការងារ ឲ្យធ្វើនៅក្នុងប្រទេស និងក្រៅប្រទេស(ផ្នែកកសិកម្ម ,ឧស្សាហកម្ម ,នេសាទ សមុទ្រ និងស្ត្រីបម្រើតាមផ្ទះ) មានប្រទេសថៃ ម៉ាឡេស៊ី ,ឥណ្ឌូនេស៊ី និងស្ត្រីពេញវ័យត្រូវបានមេខ្យល់បោកប្រាស់ តាមរយៈរៀបអាពាហ៍ពិពាហ៍ជា មួយជនបរទេស (ជនជាតិចិន កូរ៉េ និងប្រទេសមួយចំនួនទៀត) ដែលពុំមានច្បាប់អនុញ្ញាតត្រឹមត្រូវ ។

ប្រជាពលរដ្ឋរងគ្រោះទាំងនោះ ជាពិសេស បុរស ស្ត្រីនិងកុមារ ក្រោយពីបានដឹងថាចាញ់បោកគេដោយអំពើជួញដូរមនុស្ស ពួកគាត់ត្រូវស្វែងរកជំនួយអន្តរាគមន៍ពីអាជ្ញាធរដែនដី និងសមត្ថកិច្ចនៅក្នុងប្រទេស និងក្រៅប្រទេសជាបន្តបន្ទាប់ ។

នៅក្នុងខែមករា ឆ្នាំ២០១៦ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបំពេញ តួនាទី និងភារកិច្ចយ៉ាងមមាញឹក ខិតខំប្រឹងប្រែងបន្តអនុវត្តគ្រប់វិធី និងដឹកនាំជាយុទ្ធសាស្ត្រ តាមផែនការសកម្មភាពជាតិ ឆ្នាំ២០១៤-២០១៨ ដើម្បីបន្តជំរុញសកម្មភាពក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និង លិខិតបទដ្ឋាន គតិយុត្ត ការងារដឹកនាំ ស្តីពីការបង្ការ បង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការដាក់ទណ្ឌកម្មលើជនល្មើស ។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានពង្រឹងកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជំរុញការសម្របសម្រួល ជាមួយក្រុមការងារ អន្តរក្រសួង ស្ថាប័ន ព្រមទាំងរាជធានី-ខេត្ត ដើម្បីរកដំណោះស្រាយបញ្ហាប្រឈមនានាសុំឲ្យមានកិច្ចសហការស្រាវជ្រាវនូវបទល្មើស និងផលប៉ះពាល់អំពើជួញដូរមនុស្ស ។

របាយការណ៍ខាងក្រោមជាទិន្នន័យដែលទទួលបានពីក្រុមការងារអនុវត្តន៍ច្បាប់ចំនួន០១ច្បាប់ ដែលដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ និងរាជធានី/ខេត្ត ចំនួន២១ច្បាប់ គឺខេត្ត(កោះកុង ,ព្រះសីហនុ ,កំពត ,កែប ,តាកែវ ,កណ្តាល , ស្វាយរៀង ,កំពង់ឆ្នាំង ,ពោធិ៍សាត់ ,ប៉ៃលិន ,បាត់ដំបង ,បន្ទាយមានជ័យ, ឧត្តរមានជ័យ ,ព្រះវិហារ , កំពង់ធំ , ត្បូងឃ្មុំ

កំពង់ចាម ,ក្រចេះ ,ស្ទឹងត្រែង ,រតនគិរី ,មណ្ឌលគិរី) និងសកម្មភាព របស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលទទួលបានលទ្ធផល ដូចខាងក្រោម ៖

## II.លទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

នៅក្នុងខែមករា ឆ្នាំ២០១៦ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ បានបន្តយកចិត្តទុកដាក់អនុវត្តផែនការសកម្មភាព និងទិសដៅភារកិច្ចរបស់ខ្លួន ដោយពង្រឹងកិច្ចសហប្រតិបត្តិការរវាងបណ្តា ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនិងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ បានធ្វើឲ្យសម្រេចនូវលទ្ធផលដូចខាងក្រោម ៖

## ក. ការអនុវត្តយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស

**១. ការងារបង្ការ-ទប់ស្កាត់:**

**១.១.ការផ្សព្វផ្សាយ អប់រំ**

នៅក្នុងខែមករា ឆ្នាំ២០១៦នេះ ការផ្សព្វផ្សាយទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធអាជ្ញាធរ និងសមត្ថកិច្ចបានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយជាសាធារណៈ ទៅតាមគោលដៅចំនួន**១,២៣៧**លើក បើប្រៀបធៀបខែមុនក្នុងឆ្នាំ២០១៥ មានចំនួន៨១៥លើក មានការកើនឡើងចំនួន**៤២២**លើក ស្មើនឹង**៥១,៧៧%** និងមានមនុស្សចូលរួមសរុបចំនួន**១៥៤,៨៤៤**នាក់ បើប្រៀបធៀបខែមុនក្នុងឆ្នាំ២០១៥មានចំនួន**១៣៧,៩០១**នាក់ មានការកើនឡើងចំនួន**១៦,៩៤៣**នាក់ ស្មើនឹង**១២,២៨%** ក្នុងនោះស្ត្រីមានចំនួន**៩២,៨៩៨**នាក់។ (**ឧបសម្ព័ន្ធទី១**)

**១.២.ការងារបង្ការ-ទប់ស្កាត់**

- យោងលើលទ្ធផលសម្រេចបាន លើការងារបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្ស ដែលនាយកដ្ឋានជំនាញសមត្ថកិច្ចនិងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត សហការជាមួយស្ថាប័នពាក់ព័ន្ធ ទទួលបានលទ្ធផលសរុបចំនួន**៥៦២**លើកបើប្រៀបធៀបខែមុនក្នុងឆ្នាំ២០១៥ មានចំនួន៨០៦លើក មានការថយចុះ**២៤៤**លើក ស្មើនឹង**៣០,២៧%** មានមនុស្សចំនួន៣,៩៥២នាក់ បើប្រៀបធៀបខែមុនក្នុងឆ្នាំ២០១៥ មានចំនួន**១៨,១១០**នាក់ មានការថយចុះចំនួន**១៤,១៥៨**លើក ស្មើនឹង**៧៨,១៧%** ក្នុងនោះ ស្ត្រី ចំនួន ២,០៩៦ នាក់ ។(**ឧបសម្ព័ន្ធទី២**)

○ ស្នងការដ្ឋាននគរបាលខេត្ត កណ្តាល, កំពង់ចាម ,ក្រចេះ និងមណ្ឌលគិរី បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យា ហាមឃាត់ ការប្រព្រឹត្តអំពើសញ្ជារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើការងារក្នុងហាងម៉ាស្សា,ខារ៉ាអូខេ បានចំនួន**២៤៧**គោលដៅ និងមានមនុស្សចំនួន**៩៣៣**នាក់ (ស្រីចំនួន**៦៦០**នាក់)ចូលរួមស្តាប់ ។

○ បច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ទាំង២៥ រាជធានី-ខេត្តមានចំនួន**៧១**គោលដៅក្នុងនោះអំពើជួញដូរមនុស្សចំនួន**០៥** គោលដៅនិងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន**៦៦**គោលដៅ ។

○ ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានចូលរួមផ្សព្វផ្សាយ ច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន០៤លើក និងបានចុះល្បាតនៅតាមផ្សាររាត្រី តាមមាត់ស្ទឹង តាមសួន ច្បារមុខសណ្ឋាគារមហាអង្គរ (ហ្គ្រង់) ។

**២. ការងារការពារ ស្តារនីតិសម្បទាសមាហរណកម្ម និងមាតុភូមិនិវត្តន៍**

**២.១ការងារការពារ-ស្តារនីតិសម្បទាជនរងគ្រោះ**

-គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ខ.ប.ជ)បានសហការជាមួយ អង្គការដៃគូចុះជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចលើកំលាំងពលកម្មសរុបបានចំនួន**៣១**នាក់ បើប្រៀបធៀបខែមុនមានចំនួន**៧០**នាក់ មានការថយចុះចំនួន **៣៩**នាក់ ស្មើនឹង**៥៥,៧១%** ក្នុងនោះស្ត្រី មានចំនួន**២៤**នាក់។ (**ឧបសម្ព័ន្ធទី៣**)

**២.២ សមាហរណកម្ម និងមាតុភូមិនិវត្តន៍: ក្នុងខែមករា ឆ្នាំ ២០១៥ ( គ្មាន )**

២.៣ ការងារទទួលពលករខ្មែរពីអាជ្ញាធរបរទេសៈ

-ស្នងការដ្ឋាននគរបាលខេត្ត បន្ទាយមានជ័យ និងស្វាយរៀង បានទទួលការសម្ភាសពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃ និងវៀតណាមបញ្ជូនមកវិញ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកបាវិតមានចំនួន៤,៨១២នាក់(ស្រីចំនួន១,៥១៩នាក់) អនីតិជនចំនួន៣៥១នាក់ (ស្រីចំនួន៣១៥ នាក់) ក្នុងនោះមាន ៖

- ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យចំនួន៤,៨០៧នាក់ស្រីចំនួន១,៥០៩នាក់អនីតិជន៣៤២នាក់ស្រីចំនួន១១៣នាក់ ។

  -មានប្រជាពលរដ្ឋខ្មែរចំនួន៨៥នាក់ ត្រូវអាជ្ញាធរថៃ ឃាត់ខ្លួនលើសពីរយៈពេល១ខែ មុនបញ្ជូនមកកម្ពុជាវិញ។

- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀងចំនួន១៤នាក់ ស្រីចំនួន១០នាក់ អនីតិជន០៩នាក់ ស្រីចំនួន០៥នាក់ ក្រោយធ្វើការសម្ភាសរួច ពលរដ្ឋខ្មែរទាំងអស់ត្រូវបានអប់រំណែនាំឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។

៣. ការងារអនុវត្តច្បាប់

-កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស

នាយកដ្ឋានជំនាញនិងស្នងការដ្ឋាននគរបាលរាជធានី-ខេត្តព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេសខិតខំតាមដានស្រាវជ្រាវបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន០៣ករណី/០៣ករណី(បើប្រៀបធៀបខែមុនស្មើគ្នា ) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងបានចំនួន០៤នាក់(ស្រីចំនួន០២នាក់)ក្នុងនោះសញ្ជាតិអូស្ត្រាលី០១នាក់(ស្រីចំនួន០២នាក់) សង្គ្រោះជនរងគ្រោះបានចំនួន១២នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំចំនួន០១នាក់ អាយុក្រោម១៥-១៧ឆ្នាំចំនួន០១នាក់ និងអាយុ១៨ឆ្នាំឡើងចំនួន១០នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន០៧នាក់ និងចំនួន០៥នាក់ ទៀតប្រគល់ឲ្យគ្រួសារគ្រប់គ្រងវិញ )។

➢ អំពើធ្វើអាជីវកម្មផ្លូវភេទ:

សរុបចំនួន០៣ករណី/០២ករណី ជនសង្ស័យចំនួន០៤នាក់ ជនរងគ្រោះចំនួន១២នាក់ អាយុក្រោម១៥ឆ្នាំចំនួន០១នាក់ អាយុក្រោម១៥-១៧ឆ្នាំចំនួន០១នាក់ និងអាយុ១៨ឆ្នាំឡើង ចំនួន១០នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន០៧នាក់ និងចំនួន០៥នាក់ ទៀតប្រគល់ឲ្យគ្រួសារគ្រប់គ្រងវិញ )។

| | |
|---|---|
| -សញ្ជារកម្ម | ០១ករណី ជនសង្ស័យ ០១នាក់ (សញ្ជាតិអូស្ត្រាលី) |
| -សញ្ជារកម្ម(ទាក់ទងនឹងពេស្យាចារកុមារ) | ០១ករណី ជនសង្ស័យ ០២នាក់ |
| -អំពើអាសប្រាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ករណី ជនសង្ស័យ ០១នាក់ |

៤. ការងារកិច្ចការយុត្តិធម៌ កំពុងរៀបចំប្រព័ន្ធទិន្នន័យថ្មី

៥. ការងារសហប្រតិបត្តិការអន្តរជាតិ

+ខេត្ត ព្រះវិហារ ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមកិច្ចប្រជុំជាមួយសាធារណៈរដ្ឋប្រជាមានិតចិនចំនួន០១លើកស្តីពីកិច្ចសហប្រតិបត្តការអន្តរជាតិ ដែលកើតមានឡើងពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មលើមនុស្ស ការធ្វើទេសន្តរប្រវេសន៍ខុស ។

៦. ការងារពាក់ព័ន្ធនឹងកុមារ

សកម្មភាពខិតខំប្រឹងប្រែងក្នុងកិច្ចការការពារ និងជួយសង្គ្រោះដល់កុមារ ជាពិសេសកុមារងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចលើកម្លាំងពលកម្ម របស់គ.រ.ប.ជ/គ.ខ.ប.ជ សរុបបានចំនួន០៨នាក់ ក្នុងនោះជាកុមារីចំនួន០៨នាក់ ៖

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង បានផ្តល់សេវាចិញ្ចឹមកុមារ នៅមណ្ឌលបូរីកុមារកំព្រាទី១ និងមណ្ឌលបូរីកុមារកំព្រាទី២ខេត្ត ដោយមានការឧបត្ថម្ភគាំទ្រថវិការបស់រាជរដ្ឋាភិបាល អង្គការ ASPECA ប្រចាំនៅកម្ពុជា និងអង្គការ CIFA ដែលមានកុមារសរុបចំនួន២៤៣នាក់ កុមារីចំនួន១០៧នាក់ ។

+មន្ទីរសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាខេត្តពោធិ៍សាត់ បានទទួលកុមារស្នាក់នៅមានចំនួន២៦១នាក់ និងកុមារីចំនួន១២៦នាក់ ក្នុងនោះ(មណ្ឌលរដ្ឋ១ មានកុមារស្នាក់នៅសរុបចំនួន៤៧នាក់ កុមារីចំនួន២៥នាក់ មណ្ឌលអង្គការផ្សេងៗចំនួន៥ មាន កុមារស្នាក់នៅសរុបចំនួន១៣៦នាក់ កុមារីចំនួន៦០នាក់ និងមណ្ឌលអង្គការក្នុងសហគមន៍មាកុមារស្នាក់សរុបចំនួន៧៨នាក់ កុមារីចំនួន៤១នាក់) កុមារទាំងនេះបានទទួលនូវការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**៧. ការងារទេសន្តរប្រវេសន៍**

○ តាមទិន្នន័យរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិបានធ្វើការសម្ភាសពលករខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យ សុំរៀបអាពាហ៍ពិពាហ៍បានចំនួន១៨៤គូ និងបានសាកសួរសុខទុក្ខនារីខ្មែរ ដែលបានរៀបការរួចទៅនៅឯក្រៅប្រទេស ដោយបានទំនាក់ទំនងតាមរយៈទូរស័ព្ទផ្ទាល់របស់សាមីខ្លួនបានចំនួន១៦នាក់ (រស់នៅជាមួយគ្រួសារមានសេចក្តីសុខសប្បាយជាធម្មតា) ព្រមទាំងបានសម្ភាសពលករ ពលការនីរង គ្រោះចំនួន២១នាក់ ក្នុងនោះមាន ៖

-មកពីប្រទេសឥណ្ឌូណេស៊ីចំនួន១៣នាក់ ទៅដោយខ្លួនឯង ។

-មកពីប្រទេសម៉ាឡេស៊ី ចំនួន០៤នាក់ ទៅតាមរយៈក្រុមហ៊ុនចំនួន០២នាក់ ទៅតាមរយៈមេខ្យល់ចំនួន០២នាក់មិនស្គាល់អត្តសញ្ញាណ ។

-មកពីប្រទេសចិនចំនួន០៤នាក់ ទៅតាមរយៈមេខ្យល់មិនស្គាល់អត្តសញ្ញាណ ។

○ តាមទិន្នន័យរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ពលករទេសន្តរប្រវេសន៍ទៅរកការងារធ្វើនៅក្រៅប្រទេស ដែលបានគ្រប់គ្រងក្នុងខែមករា ឆ្នាំ២០១៦ សរុបបានចំនួន៤៩០,៤០៧នាក់(ស្រីចំនួន២១៧,៣០១នាក់) អនីតិជន មានចំនួន១២,០០៣នាក់ (ស្រីចំនួន ៤,៥៨០ នាក់ ) ក្នុងនោះស្របច្បាប់ ចំនួន១៧៣,៧៨៥នាក់ (ស្រីចំនួន៨១,១៦៦នាក់) និងអនីតិជនចំនួន៥៩៧នាក់ (ស្រីចំនួន២៦៣នាក់) មិនស្របច្បាប់ចំនួន៣១៦,៦២២ នាក់ (ស្រីចំនួន១៣៥,៨៦៥នាក់) និងអនីតិជនចំនួន១១,៤០៦នាក់ ( ស្រីចំនួន៤,៣១៧នាក់ ) បើប្រៀបធៀប នឹងខែមុនកើនឡើងចំនួន ៣៩,៥៦២នាក់ ស្មើនឹង៨,៧៧ % ។

## ខ.ការងារដឹកនាំសម្របសម្រួល

ការងារដឹកនាំសម្របសម្រួលសរុបរួមបានចំនួន៣៩លើក ក្នុងខែមករា ឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ និង គណៈកម្មាធិការរាជធានី-ខេត្ត គ.រ.ប.ជ/គ.ខ.ប.ជ ។ (**ឧបសម្ព័ន្ធទី៧**)

❖ គណៈកម្មាធិការជាតិ គ.ជ.ប.ជ ៖

**+សកម្មភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

-បានដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងអគ្គលេខាធិការ គ.ជ.ប.ជ លើរបាយការណ៍ថ្នាក់ជាតិពាក់ព័ន្ធអំពើជួញ ដូរមនុស្សឆ្នាំ២០១៦ នៅសាលប្រជុំ របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។

-បានទទួលជួបក្រុមការពារកុមារ ពីអង្គការ unicef ពិភាក្សាអំពីការជួញដូរកុមារតាមប្រព័ន្ធអ៊ីនធឺណែត ។

-បានចូលរួមក្នុងកម្មវិធីការថ្លែងអំណរគុណសម្រាប់ភាពជាដៃគូ ក្នុងការប្រយុទ្ធប្រឆាំងអំពើធ្វើអាជីវកម្មផ្លូវភេទលើអនីតិជនក្នុងប្រទេសកម្ពុជា ចាប់ពីឆ្នាំ២០០៣ ដល់២០១៦ រៀបចំ ដោយអង្គការបេសកកម្ម យុត្តិធម៌អន្តរជាតិ (IJM) ។

-បានចូលរួមជំនួបពិភាក្សាថ្នាក់ដឹកនាំជាន់ខ្ពស់នៃ គ.ជ.ប.ជ ជាមួយប្រតិភូអង្គការបេសកកម្មអន្តរជាតិ (IJM) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ ។

-បានអញ្ជើញជាគណៈអធិបតី ក្នុងពិធីបិទសន្និបាតបូកសរុបការងារប្រចាំឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦ របស់រដ្ឋបាលខេត្តកំពង់ធំ ។

+ខេត្ត **បន្ទាយមានជ័យ** ការិយាល័យជំនាញប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការអនីតិជន បានធ្វើការប្រជុំជាមួយក្រុមការងារទី៤នៃនាយកដ្ឋានកណ្តាលយុត្តិធម៌ ស្តីពីការពិនិត្យផ្ទៀងផ្ទាត់បញ្ជីឯកសារ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស នៅក្រសួងមហាផ្ទៃ ។

+ខេត្ត **បាត់ដំបង** បានសហការជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការ Cambodia ACTs រៀបចំកិច្ចប្រជុំពិនិត្យការអនុវត្តការងារឆ្លើយតបរបស់មន្ត្រីនគរបាលជួរមុខ និងអ្នកពាក់ព័ន្ធ ក្រោយការបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកដោយមិនមានសុវត្ថិភាព ដែលមានអ្នកចូលរួមសរុបចំនួន៣៨នាក់ ស្រីចំនួន១០នាក់ ។

+ខេត្ត **សៀមរាប** បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីសកម្មភាពថ្នាក់ភូមិ ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស អំពីការធ្វើចំណាកស្រុកខុសច្បាប់ និងការស្វែងស្វែងរកសេវាគាំទ្រ ដែលរៀបចំដោយក្រសួងកិច្ចការនារីខេត្តកំពង់ធំ។

+ខេត្ត **ស្វាយរៀង** គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានចូលរួមប្រជុំជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ស្តីពីការពាក់ព័ន្ធទិន្នន័យការបង្ការ ការបង្រ្កាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការប្រៀបធៀបតារាងបទល្មើសឆ្នាំ២០១៤ -ឆ្នាំ២០១៥ និងទិសដៅការងារឆ្នាំ២០១៦ នៅស្នងការនគរបាលខេត្តព្រៃវែង ។

+ខេត្ត **ត្បូងឃ្មុំ** គណៈបញ្ជាការឯកភាព និងជាប្រធាន គ.ខ.ប.ជ ខេត្ត បានធ្វើកិច្ចប្រជុំ ស្តីពីការពង្រឹងសមត្ថភាព និងមានវិធានការយ៉ាងតឹងរឹងដល់គ្រប់សមត្ថកិច្ចពាក់ព័ន្ធតាមច្រកអន្តជាតិត្រពាំងផ្លុង តាមច្រករបៀងនៅជាប់ព្រំដែនវៀតណាម និងតាមបណ្តាក្រុង/ស្រុក ដើម្បីការការពារ ទប់ស្កាត់អំពើជួញដូរមនុស្ស ។

## ឃ. ការលើកកម្ពស់សមត្ថភាព

### ១.ការបណ្តុះបណ្តាល

គណៈកម្មាធិការជាតិ (គ.ជ.ប.ជ) ស្ថាប័នពាក់ព័ន្ធ និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការរាជធានី (គ.រ.ប.ជ)និង គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូ និងបានចាត់មន្ត្រីជាគ្រូឧទ្ទេសចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់សិក្ខាកាមជាមន្ត្រីក្រុមប្រឹក្សាឃុំ មន្ត្រីថ្នាក់មូលដ្ឋាន មន្ត្រីលេខាធិការដ្ឋានខេត្ត មន្ត្រីអនុវត្តន៍ច្បាប់ គ្រូបង្គោល និងបុគ្គលិកនៃបណ្តាអង្គការបានចំនួន០១លើកមានអ្នក ចូលរួមសរុបចំនួន ៤១នាក់ ក្នុងនោះមានស្ត្រីចំនួន៣៦ នាក់ ។

+គណៈកម្មាធិការជាតិ គ.ជ.ប.ជ ៖ (គ្មាន)

+ខេត្ត **កំពង់ធំ** គណៈកម្មាធិការ គ.ខ.ប.ជ បានបើកវគ្គបណ្តុះបណ្តាលដល់គ្រូបង្គោលថ្នាក់តំបន់ខេត្ត ស្តីពីការពង្រឹងសមត្ថភាពថ្នាក់ភូមិ ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទបានចំនួន០១លើកមានអ្នកចូលរួមចំនួន៤១នាក់ស្រីចំនួន៣៦នាក់។

### ២. សិក្ខាសាលា

+ខេត្ត **តាកែវ** បានធ្វើសិក្ខាសាលាបណ្តាញភូមិ/ឃុំសុវត្ថិភាព ស្តីពីវិធានការទប់ស្កាត់ និងការការពារប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអ្នកចូលរួមចំនួន៥៥នាក់ ស្រីចំនួន២៨នាក់ មានការសហការដោយអង្គការ VCAO គាំ។

## III. ការវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង ក្នុងខែមករា ឆ្នាំ២០១៦នេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចបានការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

១. បានប្រកាសជាផ្លូវការ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គណៈកម្មាធិការរាជធានី-ខេត្តគ.រ.ប.ជ/គ.ខ.ប.ជ លេខាធិការដ្ឋានគ.រ.ប.ជ/គ.ខ.ប.ជ ប្រកាសសេចក្តីសម្រេចកំណត់តួនាទី ភារកិច្ចរួមជាស្រេច។

២. បានដាក់ចុះផែនការសកម្មភាពជាតិ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)សម្រាប់រយៈពេល៥ ឆ្នាំ (២០១៤-២០១៨) ជាផែនទីបង្ហាញផ្លូវ ។

៣. បានរៀបចំក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នឹងបន្តសកម្មភាពដឹកនាំជាយុទ្ធសាស្ត្រ របស់ក្រុមការងារ ទាំង ៦ និងថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការរួមគ្នា លើកវិធានការ ការងារបង្ការទប់ស្កាត់និង បង្ក្រាបបទល្មើសជួញដូរមនុស្ស ។

៤. បានបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយអន្តរក្រសួង ស្ថាប័ននានា ក្នុងដំណើរការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៥. កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអនុវត្តន៍ច្បាប់ ដែលបានអនុវត្តទៅតាមតួនាទី និងភារកិច្ចដែលបានដាក់ចុះសម្រេចបាននូវលទ្ធផលគួរឲ្យកត់សម្គាល់។

៦. បានខិតខំស្វែងរកការគាំទ្រ និងកិច្ចសហការពីអង្គការជាតិ អន្តរជាតិ ជាដៃគូនានា សំដៅអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព។

**ខ.ចំណុចសេសសល់ នឹងភាពប្រឈម**

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

១. ក្រុមការងារអន្តរក្រសួងស្ថាប័ន ព្រមទាំងលេខាធិការដ្ឋានរាជធានី-ខេត្ត មួយចំនួនមិនទាន់បានឆ្លើយតបលទ្ធ ផល ការងារតាមរយៈរបាយការណ៍តាមការកំណត់ នៅឡើយ ។

២. កង្វះខាតសម្ភារការិយាល័យនៅក្នុងលេខាធិការដ្ឋាន ដូចជា តុ កៅអី ទូដាក់ឯកសារ កុំព្យូទ័រ ម៉ាស៊ីនព្រីន ម៉ាស៊ីនថតចម្លង និងសម្ភារផ្សេង ៗ ។

៣. កង្វះខាតមធ្យោបាយទំនាក់ទំនង ការងារជាមួយបណ្តាអង្គភាពពាក់ព័ន្ធ អន្តរក្រសួងនិង រាជធានី ខេត្ត មាន ៖ ម៉ាស៊ីន Fax ,Phone ករណីខាងលើនេះទាមទារឲ្យគ្រប់ក្រុមការងារ ពិនិត្យរាល់ភាពខ្វះចន្លោះរកចំណុច គន្លឹះរៀបចំវិធាន ការ ជំរុញការដឹកនាំជាក់ស្តែងដើម្បី អនុវត្តសកម្មភាពបន្ត ។

## IV.ទិសដៅសម្រាប់ខែកុម្ភៈ ឆ្នាំ ២០១៦

១. បន្តជំរុញការរៀបចំរចនាសម្ព័ន្ធ ក្រុមការងារថ្នាក់ជាតិ មានក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងថ្នាក់ក្រោមជាតិ រាជធានី- ខេត្ត ទាំង ២៥ ។

២. បើកវគ្គបណ្តុះបណ្តាលជូនដល់មន្ត្រីអគ្គលេខាធិការដ្ឋាន អំពីរបៀបរបបការងារចំណេះដឹង ជាមូលដ្ឋានក្នុងការអនុវត្តយុទ្ធ សាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៣. បើកវគ្គបណ្តុះបណ្តាល ជូនដល់មន្ត្រីលេខាធិការដ្ឋាន ថ្នាក់ក្រោមជាតិ អំពីបែបបទ បទដ្ឋានប្រមូលនិងចងក្រងឯកសារទាក់ទិននឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៤. បន្តយកចិត្តទុកដាក់ ជំរុញការផ្សព្វផ្សាយ ការបង្ការទប់ស្កាត់ ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីអំពើជួញដូរមនុស្ស និងបញ្ហាទេសន្តរប្រវេសន៍ការងារជាពិសេសចំពោះជនដែលងាយរងគ្រោះ។

៥. បន្តជំរុញការលើកកម្ពស់សមត្ថភាព ដល់មន្ត្រីអនុវត្តន៍ច្បាប់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីមានសមត្ថភាពគ្រប់គ្រាន់ រួមចំណែកក្នុងសកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទ លើស្ត្រី និងកុមារ ។

៦.ជំរុញការបោះពុម្ពផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ជាមូលដ្ឋានគ្រឹះសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ។

៧.បន្តជំរុញណែនាំក្រុមការងារថ្នាក់ជាតិ និងលេខាធិការដ្ឋាន រាជធានី-ខេត្ត ឲ្យអនុវត្តតាមផែនការសកម្មភាព របស់ខ្លួនដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សសម្រាប់ឆ្នាំ ២០១៤-២០១៨ ។

៨.បន្តពង្រឹងកិច្ចសហប្រតិបត្តិការល្អ ជាមួយបណ្តាអង្គការជាតិ អន្តរជាតិ និងអង្គការដៃគូពាក់ព័ន្ធ បន្តបើកវគ្គបណ្តុះណ្តាលច្បាប់ដល់មន្ត្រីជំនាញ និងស្ថាប័នពាក់ព័ន្ធ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ។

៩.លើកកម្ពស់ការអនុវត្ត គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពឲ្យបានល្អនៅថ្នាក់មូលដ្ឋានដោយពង្រឹងការបង្ការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្សដែលអាចកើតមានក្រោមទម្រង់ការកេងប្រវ័ញ្ចផ្សេងៗ។

**បានឃើញ និង ឯកភាព**

រាជធានីភ្នំពេញ ថ្ងៃទី........ខែ.........ឆ្នាំ២០១៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ ប៊ុនអេង

រាជធានីភ្នំពេញ ថ្ងៃទី........ខែ........ឆ្នាំ២០១៦

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក.ថោង សំអាត

**ចម្លងជូន**

-ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ "ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## ការងារផ្សព្វផ្សាយ

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | លើក | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារ អនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ភូមិ-ឃុំមានសុវត្ថិភាព ដល់ម្ចាស់អាជីវកម្ម អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ។ | ស្នងការដ្ឋាននគរបាលខេត្ត | 269 លើក | 22,443 នាក់ | 11,584 នាក់ |
| 2 | កណ្តាល | មន្ទីកិច្ចការនារីខេត្តបានសហការជាមួយ គម្រោង( PADEE )និង ជាមួយអង្គការត្រាស់ផ្សព្វផ្សាយច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ ។ | មន្ទីកិច្ចការនារី | 32 លើក | 1,678 នាក់ | 1,325 នាក់ |
| | | ក្រុមការងារ បានធ្វេការផ្សព្វផ្សាយតាមវេទិការសាធារណៈច្បាប ស្តពីការប្រយុទ្ធប្រឆាងអពេជួញដូរមនុស្ស ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ទប់ស្កាត់ការឆក់ប្លន់ ល្បែង /ស៊ីសង ដល់ក្រុមប្រឹក្សា ឃុំ ភូមិ និងប្រជាជន ។ | ស្នងការដ្ឋាននគរបាលខេត្ត | 36 លើក | 6,490 នាក់ | 2,805 នាក់ |
| 3 | កែប | បានបញ្ជ្រាបការទប់ស្កាត់ការធ្វើចំណាក់ស្រុកដោយខុសច្បាប់ជូនដល់ប្រជាពលរដ្ឋនិងផ្សព្វផ្សាយការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈវេទិការផ្សព្វផ្សាយគោលនយោបាយភូមិ,ឃុំ,មានសុវត្ថិភាព ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | 67 នាក់ | 55 នាក់ |
| 4 | រតនះគីរី | ក្រុមការងារអនុវត្តន៍ច្បាប់ ដែលដឹកនាំដោយលោកស្នងការ នៃស្នងការដ្ឋាននគរបាលខេត្តបានធ្វើការផ្សព្វផ្សាយតាមវេទិការសាធារណៈដល់ប្រជាជនអំពីច្បាប់ប្រឆាំងការជួញដូរមនុស្ស | ស្នងការដ្ឋាននគរបាលខេត្ត | 3 លើក | 312 នាក់ | 99 នាក់ |
| 5 | កំពង់ឆ្នាំង | បានធ្វើវេទិកាសាធារណៈ ភូមិ-ឃុំមានសុវត្ថិភាពស្តីអំពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដែលមានសមាសភាពចូលរួមមន្ត្រីរាជការ អង្គការសង្គមស៊ីវិល ,កងកម្លាំងប្រដាប់អាវុធ ,អាជ្ញាធរ ភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ | ស្នងការដ្ឋាននគរបាលខេត្ត | 500 លើក | 69,237 នាក់ | 48,911 នាក់ |
| 6 | តាកែវ | បានធ្វើវេទិកាសាធារណៈ ភូមិ-ឃុំមានសុវត្ថិភាព ដែលមានសមាសភាពចូលរួមមន្ត្រីរាជការ អង្គការសង្គមស៊ីវិល ,កងកម្លាំងប្រដាប់អាវុធ ,អាជ្ញាធរ ភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 13 លើក | 897 នាក់ | 262 នាក់ |
| | | បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សា ការធ្វើចំណាកស្រុកខុសច្បាប់ និងការ ជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋនៅក្នុងស្រុកសំរោង ។ | មន្ទីកិច្ចការនារីខេត្ត | 1 លើក | 25 នាក់ | 16 នាក់ |
| 7 | បាត់ដំបង | បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីអនុវត្តន៍គោលនយោបាយភូមិ / ឃុំ មានសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មលើស្ត្រី និងកុមារ ការធ្វើការចំណាកស្រុកដោយសុវត្ថិភាព ដល់កងកំលាំង ប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 193 លើក | 24,693 នាក់ | 12,059 នាក់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 8 | កំពត | បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មលើស្ត្រី និងកុមារការធ្វើការចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាជនស្រុកអង្គជ័យ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីកិច្ចការនារី | 1 | លើក | 101 នាក់ | 19 នាក់ |
| 9 | ពោធិ៍សាត់ | បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈភូមិ/ឃុំមានសុវត្ថិភាព ក្រុងពោធិ៍សាត់ ស្រុក ក្រគរ ស្រុកកណ្តៀង ស្រុកភ្នំក្រវាញ ស្រុកបាកាន ស្រុកវាលវែង ដោយមានការចូលរួម ពីប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស | លេខាធិការដ្ឋាន គ.ខ.ប.ជ | 128 | លើក | 24,981 នាក់ | 13,598 នាក់ |
| 10 | | បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈវេទិការសាធារណៈ ក្រុងពោធិ៍សាត ស្រុកក្រគរ ភ្នំក្រវាញ បាកាន | | 9 | លើក | 692 នាក់ | 174 នាក់ |
| 11 | កំពង់ចាម | បានធ្វើការផ្សព្វផ្សាយ ពីការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស នៅឃុំ ទងត្រឡាច ស្រុកស្រីសន្ធរ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 1 | លើក | 33 នាក់ | 10 នាក់ |
| 12 | សៀមរាប | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត មន្ទីរ-អង្គភាពពាក់ព័ន្ធ អាជ្ញាធរក្រុង-ស្រុក និងអង្គការ ដៃគូនានា ចុះធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ,ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ,កិច្ចការពារជនរងគ្រោះ ,ការជួញដូរស្ត្រី និងកុមារ ,អំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមបណ្តាប៉ុស្តិ៍នគរបាលទាំង ១៣សង្កាត់ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីសង្គមកិច្ច | 3 | លើក | 140 នាក់ | 45 នាក់ |
| 13 | ត្បូងឃ្មុំ | ធ្វើវេទិការសាធារណៈស្តីពី ការអនុវត្តន៍គោលនយោបាយភូមិឃុំ/មានសុវត្ថិភាពក្នុងនោះបានសង្កត់ធ្ងន់លើការងារចំណាក់ស្រុកដោយប្រថុយប្រថាន ដល់កងកំលាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ | គណៈកម្មាធិការ គ.ខ.ប.ជ | 8 | លើក | 786 នាក់ | 486 នាក់ |
| 14 | ព្រះសីហនុ | ក្រុមការងារ ( គ ខ ប ជ ) បានសហការជាមួយអាជ្ញាធរក្រុង /ស្រុកតាមរយៈការផ្សព្វផ្សាយ គោលនយោបាយភូមិឃុំ មានសុវត្ថិភាព និងអង្គការជាដៃគូរ ផ្សព្វផ្សាយអំពីការរំលោភបំពានផ្លូវភេទ និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ការចំណាក់ស្រុកខុសច្បាប់ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 18 | លើក | 634 នាក់ | 225 នាក់ |
| | | ក្រុមការងារបានចូលរួមផ្សព្វផ្សាយវេទិការសារធារណៈភូមិឃុំមានសុវត្ថភាព ដល់កំលាំងសមត្ថកិច្ច មន្ត្រីរាជការ អង្គការ សង្គមស៊ីវិល លោកគ្រូ /អ្នកគ្រូ និងប្រជាជន | | 6 | លើក | 330 នាក់ | 84 នាក់ |
| 15 | កោះកុង | ក្រុមការងារបានចូលរួមផ្សព្វផ្សាយវេទិការសារធារណៈភូមិឃុំមានសុវត្ថភាព ដល់កំលាំងសមត្ថកិច្ច មន្ត្រីរាជការ ភូមិ/ឃុំ/សង្កាត់ និងប្រជាជន ។ | | 15 | លើក | 1,305 នាក់ | 1,141 នាក់ |

សកម្មភាពសរុបចំនួន: 1,237 លើក

មនុស្សសរុបចំនួន: 154,844 នាក់

ស្រីសរុបចំនួន: 92,898 នាក់

# ឧបសម្ព័ន្ធទី២

## ការទារបង្ការទប់ស្កាត់

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | កន្លែង/ គោលដៅ | មនុស្សសរុប | ស្ត្រី |
|---|---|---|---|---|---|---|
| ១ | ស្វាយរៀង | បានចុះផ្សព្វផ្សាយសេចក្តីណែនាំ លេខ០០៥ របស់អគ្គស្នងការនគរបាលជាតិដល់ម្ចាស់ ខារ៉ាអូខេ សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួលម៉ាស្សា កោសជប់ លក់វីស៊ីឌី ចុះផ្សព្វផ្សាយសេចក្តីច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ទេសន្តប្រវេសន៍ និងកុមារបម្លាស់ទីដល់ប្រជាពលរដ្ឋ | ស្នងការនគរបាលខេត្ត | 8 លើក | 71 នាក់ | 50 នាក់ |
| 2 | កណ្តាល | បានចុះផ្សព្វផ្សាយវេទិកាសាធារណៈ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការលប់បំបាត់ពលកម្មកុមារ ក្នុងទំរង់ធ្ងន់ធ្ងរការធ្វើអាជីវកម្មផ្លូវភេទ ស្ត្រីកុមារ ដល់ប្រជាពលរដ្ឋ ។ | លេខាធិការដ្ឋាន | 72 លើក | 1,581 នាក់ | 692 នាក់ |
| | | បន្តការគ្រប់គ្រងតាមសណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល កន្លែងម៉ាស្សា កោសជប់ ខារ៉ាអូខេ ដើម្បីបង្ការទប់ស្កាត់ ការជួញដូរមនុស្ស | លេខាធិការដ្ឋាន | 52 លើក | 184 នាក់ | 104 នាក់ |
| 3 | កែប | បានចាត់តាំងកំលាំងចុះល្បាត និងក្តាប់សភាពការណ៍តាមបណ្តាគោលដៅសង្ស័យ ធ្វើសញ្ញាកម្មទូទាំងខេត្តជាប្រចាំបានធ្វើស្ថិតិ((សណ្ឋាគារ. ផ្ទះសំណាក់. ខារ៉ាអូខេ .ម៉ាស្សា .ភោជនីយដ្ឋាន . អាហារដ្ឋាន .ហាងកាហ្វេ និងក្លឹបកំសាន្ត ) | ស្នងការនគរបាលខេត្ត | 17 លើក | 180 នាក់ | 151 នាក់ |
| 4 | កំពង់ឆ្នាំង | ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការនគរបាលខេត្ត បានចុះបិទផ្សាយច្បាប់ស្តីពីៈ (សណ្ឋាគារ. ផ្ទះសំណាក់. ខារ៉ាអូខេ .ម៉ាស្សា .ភោជនីយដ្ឋាន .អាហារដ្ឋាន .ហាងកាហ្វេ និងក្លឹបកំសាន្ត ។ | ស្នងការនគរបាលខេត្ត | 5 លើក | 39 នាក់ | គ្មាន |
| 5 | រតនៈគិរី | ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការនគរបាលខេត្តបានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មលើស្ត្រី និងកុមារ ដល់បណ្តាអាជីវកម្ម ហាងខារ៉ាអូខេ និងក្លឹបកំសាន្ត | ស្នងការដ្ឋាននគរបាលខេត្ត | 16 លើក | 141 នាក់ | 20 នាក់ |
| 6 | បន្ទាយមានជ័យ | ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានសហការជាមួយអធិការ ដ្ឋាននគរបាលស្រុកម៉ាឡៃ បានចុះធ្វើការហាមឃាត់ពលរដ្ឋមកពីខេត្តកំពង់ធំធ្វើចំណាកស្រុកខុសច្បាប់ ទៅ ធ្វើការនៅប្រទេសថៃ នៅចំណុចភូមិសាស្ត្រស្រុកម៉ាឡៃ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | 19 នាក់ | 6 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 7 | បាត់ដំបង | កំលាំងសមត្ថកិច្ចនគរបាលខេត្ត បានចុះល្បាតខ្សែបន្ទាត់ព្រំដែន របស់វរៈនគបាលការពារបរដែន គោកវរៈចេនាតូចលេខ ៨១៧ ,៨១៩ ,និង៣១០ បានចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនតាមភូមិសាស្ត្ររបស់ខ្លួនបាន ចំនួន៧៣លើក ក្នុងនោះបានទប់ស្កាត់ប្រជាពលរដ្ឋឆ្លងដែនខុសច្បាប់បាន២លើក | ស្នងការដ្ឋាននគរបាលខេត្ត | 2 លើក | 11 នាក់ | 5 នាក់ |
| 8 | ពោធិ៍សាត់ | បានចុះល្បាតត្រួតពិនិត្យ ដល់ម្ចាស់អាជីវកម្មសង្ស័យពាក់ព័ន្ធបទល្មើសផ្លូវភេទ ទៅដល់ បណ្តាអាជីវកម្ម សណ្ឋាគារ ខារ៉ាអូខេ ផ្ទះសំណាក់ ផ្ទះជួល ម៉ាស្សា កោសជប់ ផ្ទះលក់ការហ្វេ និងជួលលក់វីស៊ីឌី | ស្នងការដ្ឋាននគរបាលខេត្ត | 179 លើក | 807 នាក់ | 591 នាក់ |
| 9 | ក្រចេះ | កំលាំងសមត្ថកិច្ចនគរបាលខេត្ត បានចុះត្រួតពិនិត្យតាមសណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល ហាងម៉ាស្សា ក្លឹបខារ៉ាអូខេ និងនារីផ្សព្វផ្សាយស្រាបៀរ ដែលមានចំនួន២០៦៥បន្ទប់ | ស្នងការដ្ឋាននគរបាលខេត្ត | 193 លើក | 768 នាក់ | 507 នាក់ |
| 10 | ស្ទឹងត្រែង | បានចុះល្បាតត្រួតពិនិត្យ ទប់ស្កាត់ដល់ពលករមកពីខេត្តពោធិ៍សាត់ដែលធ្វើការខុសច្បាប់ នៅក្នុងក្រុមហ៊ុនរ៉ាវអគ្គិសនីរបស់ប្រទេសឡាវ ដោយបានណែនាំឲ្យទៅស្រុកវិញ ។ | ស្នងការដ្ឋាននគរបាលលខេត្ត | 1 លើក | 10 នាក់ | គ្មាន នាក់ |
| 11 | រតនៈគិរី | ការិយាល័យជំនាញប្រឆាំងការជួញដូរមនុស្ស នៃស្នងការដ្ឋាននគរបាលខេត្ត បានធ្វើការផ្សព្វផ្សាយអំពីច្បាប់ប្រឆាំងការជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ដល់បណ្តាអាជីវកម្មហាងខារ៉ាអូខេ និងតន្ត្រីកំសាន្ត | ស្នងការដ្ឋាននគរបាលលខេត្ត | 16 លើក | 141 នាក់ | 20 នាក់ |

សកម្មភាពសរុបៈ 562 លើក

មនុស្សសរុបចំនួនៈ 3,952 នាក់

ស្រីសរុបចំនួនៈ 2,096 នាក់

## ឧបសម្ព័ន្ធទី៣

## ការងារការពារស្តារនីតិសម្បទា ជនរងគ្រោះ

| ល.រ | អង្គភាព | សកម្មភាព | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|
| 1 | ត្បូងឃ្មុំ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានទទួលប្រជាជនត្រឡប់មកពីប្រទេសម៉ាឡេស៊ី ដែលទៅធ្វើការដោយខុសច្បាប់តាមរយៈស្ថានទូតខ្មែរប្រចាំនៅប្រទេសម៉ាឡេស៊ី ដោយបានធ្វើការអប់រំណែនាំ និងធ្វើកិច្ចសន្យា ឲ្យត្រឡប់ទៅផ្ទះវិញ។ | 2 នាក់ | 2 នាក់ |
| 2 | កែប | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានទទួលប្រជាជនត្រឡប់មកពីប្រទេសថៃ ដែលទៅធ្វើការដោយខុសច្បាប់ និងប្រជាជនទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ។ | 4 នាក់ | 4 នាក់ |
| 3 | សៀមរាប | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានទទួលស្ត្រីរងគ្រោះក្នុងករណីសញ្ជាកម្ម ពីការិយាល័យប្រឆាំង ជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត ដែលទៅធ្វើការដោយខុសច្បាប់ និងប្រជាជនទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ។ | 4 នាក់ | 4 នាក់ |
| 4 | បន្ទាយមានជ័យ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានទទួលស្ត្រីរងគ្រោះដោយជួញដូរមនុស្ស ដែលអាជ្ញាធរថៃបាន បញ្ជូនមកវិញ ។ | 6 នាក់ | 2 នាក់ |
| 5 | បាត់ដំបង | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត និអាជ្ញាធរឃុំកំរៀង ស្រុកំរៀង បានសហការជាមួយអង្គការ WVC មានគម្រោងសង់ផ្ទះជូនដល់គ្រួសារជនរងគ្រោះ ក្នុងករណីជួញដូរកម្លាំងពលកម្ម នៅប្រទាសឥណ្ឌូនេស៊ី ។ | 1 នាក់ | 1 នាក់ |
| | | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបានចូលរួមសហការជាមួយអង្គការ AIM ស្វែងរកគ្រួសារក្មេងរងគ្រោះក្នុងករណីជួញដូរផ្លូវភេទ ជនរងគ្រោះរស់នៅក្នុង ភូមិអូរតាគាំ ២ សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង និងប៉ាន់ប្រមាណពី តម្រូវការគ្រួសារដើម្បីស្តារសុខភាពផ្លូវចិត្តក្មេងរងគ្រោះ ។ -បានសហការជាមួយអង្គការ HAGAR បានចុះប៉ាន់ប្រមាណតម្រូវការគ្រួសារក្មេងស្រីរងគ្រោះក្នុងករណីកេងប្រវ័ញ្ចផ្លូវភេទ ដែលដែលរស់នៅ ភូមិ អូរចារ សង្កាត់អូរចារ ក្រុងបាត់ដំបង | 2 នាក់ | 2 នាក់ |
| 6 | ស្វាយរៀង | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានទទួលប្រជាជនឆ្លងដែនខុសច្បាប់ចំនួនមួយលើក ដែលទៅតាមច្រកទ្វារអន្តរជាតិបាវិត មានចំនួន០៤គ្រួសារ ដែលបានសហការជាមួយអង្គការ CCPCR ដោយបានធ្វើការអប់រំណែនាំ និងធ្វើកិច្ចសន្យាអោយត្រឡប់ទៅផ្ទះវិញ ។ | 12 នាក់ | 9 នាក់ |

មនុស្សសរុបចំនួន: 31 នាក់

ស្រីសរុបចំនួន: 24 នាក់

## ឧបសម្ព័ន្ធទី៥

## កិច្ចការកុមារ

| ល.រ | អង្គភាព | សកម្មភាព | ចំនួនមនុស្ស | កុមារី |
|---|---|---|---|---|
| 1 | កណ្តាល | មន្ទីរសង្គមកិច្ចបានសហការជាមួយអង្គការមេត្រីអន្តរជាតិ ដើម្បីអាស៊ីចុះប៉ាន់ប្រមាណគ្រួសារកុមារី ០១នាក់នៅស្រុកលើកដែក រងគ្រោះដោយអំពើជួញដូរ ដែលកំពុងទទួលសេវាថែទាំព្យាបាល និងបណ្តុះបណ្តាលនៅមណ្ឌលអង្គការមេត្រីអន្តរជាតិ ដើម្បីអាស៊ីភ្នំពេញ ។ បានទទួលកុមារីជនជាតិវៀតណាម រងគ្រោះដោយអំពើជួញដូរពីអង្គការមេត្រីអន្តរជាតិ ដើម្បីអាស៊ីភ្នំពេញ និងបានបញ្ជូនទៅស្រុកកំណើតរបស់ពួកគេវិញ ។ | ៦ នាក់ | ៦ នាក់ |
| 2 | បន្ទាយមានជ័យ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានទទួលកុមាររងគ្រោះដោយជួញដូរមនុស្ស ដែលអាជ្ញាធរថៃបាន បញ្ជូនមកវិញ ។ | 2 នាក់ | 2 នាក់ |

មនុស្សសរុបចំនួន: 8 នាក់

កុមារីសរុបចំនួន: 8 នាក់

# តារាងឧបសម្ព័ន្ធទី៧

## ការងារដឹកនាំសម្របសម្រួល

| | | | |
|---|---|---|---|
| 'គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | បានដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន លើរបាយការណ៍ថ្នាក់ជាតិពាក់ព័ន្ធអំពើជួញដូរមនុស្សឆ្នាំ ២០១៦ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ | 1 លើក | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងលេខាធិការដ្ឋាន |
| | បានអមដំណើរលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ ចូលរួមជំនួបរវាងថ្នាក់ ដឹកនាំជាន់ខ្ពស់នៃ គ.ជ.ប.ជ ជាមួយប្រតិភូ អង្គការបេសកកម្មអន្តរជាតិ (IJM) នៅទៅស្តីការក្រសួង មហាផ្ទៃ ។ | 1 លើក | |
| | បានចាតបញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន ០៣រូប លោកឧត្តមសេនីយត្រី សុខ រស្មី លោកវរសេនីយ៍ឯក កែវ ផល្លា និងលោក អ៊ឹង ហាក់លាង ចុះទៅខេត្តព្រះវិហារ ដើម្បីធ្វើជា គ្រូបង្គោលបណ្តុះបណ្តាលកងកម្លាំងនគរបាលវរៈ សេនាតូចការពារព្រំដែនគោក រយៈពេល១ថ្ងៃ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើទេសន្តប្រវេសន៍ ការរត់ពន្ធមនុស្ស យន្តការជាតិ-រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់ គ.ជ.ប.ជ តាំងពីថ្នាក់ជាតិរហូត ដល់ថ្នាក់ ក្រោមជាតិ នៅទីបញ្ជាការដ្ឋាននគរបាលជាតិប្រចាំទិសភូមិភាគ៤ កន្ទួត ខេត្តព្រះវិហារ មានសិក្ខាកាមចូលរួម សរុបចំនួន ៣៤០នាក់ ។ | 1 លើក | |
| | ចូលរួមបូកសរុបរបាយការណ៍ថ្នាក់ជាតិ ពាក់ព័ន្ធអំពើជួញដូរមនុស្សឆ្នាំ២០១៥ ។ | 1 លើក | លេខាធិការដ្ឋាន គ.ជ.ប.ជ |
| | បានធ្វើលិខិតជូនអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ៖ លិខិតចេញ (២២ច្បាប់) លិខិតចូល (២២ច្បាប់) បេសកកម្ម(០១ច្បាប់) បង្គាប់ការ(០១ច្បាប់) ទិដ្ឋាការធ្វើដំណើរ (០៥ច្បាប់) ។ | 1 លើក | |
| | បានចូលរួមស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានសកម្មភាពការងារជាប្រចាំ របស់មន្ត្រីនៅក្នុងអគ្គលេខាធិការដ្ឋាន ។ | 1 លើក | |

| | | | |
|---|---|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | បានធ្វើកំណត់ហេតុ ជារៀងរាល់កិច្ចប្រជុំ ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ និងខែ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានធ្វើសំណើសុំប័ណ្ណចេញ-ចូលរបស់ក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ និងបានចែកជូនថ្នាក់ដឹកនាំ និងមន្ត្រីនៃ គ.ជ.ប.ជ ។ ប្រមូលរបាយការណ៍ខែធ្នូ ឆ្នាំ២០១៥ តាមបណ្តា អន្តរក្រសួង និងរាជធានី-ខេត្ត ដើម្បីបញ្ចប់របាយការណ៍ខែធ្នូ ឆ្នាំ២០១៥ របស់ គ.ជ.ប.ជ និងបូកសរុប របាយការណ៍ប្រចាំឆ្នាំ២០១៥ របស់ គ.ជ.ប.ជ ។ | 1 លើក | លេខាធិការដ្ឋាន គ.ជ.ប.ជ |
| | បានទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកសំណើសុំថវិការៀបចំកិច្ចប្រជុំថ្នាក់ជាតិស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ។ | 1 លើក | |
| | បានទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ លើសំណើសុំឯកសណ្ឋាន ថ្នាក់អគ្គលេខាធិការរងចំនួន ០៤រូប របស់អគ្គលេខធិការដ្ឋាន គ.ជ.ប.ជ ។ | 1 លើក | |
| | បានទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ លើសំណើសុំតែងតាំងមន្ត្រីរដ្ឋបាលស៊ីវិល របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន ០៦រូប ។ | 1 លើក | |
| | បានបង្កើតទំព័រ facebook របស់លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងបន្តរៀបចំគម្រោងផែនការ សកម្មភាព និងថវិកាចំណាយរបស់ គ.ជ.ប.ជ ឆ្នាំ២០១៦ ។ ប្រមូលរបាយការណ៍តាមបណ្តា រាជធានី/ ខេត្ត តាមប្រព័ន្ធ Telegram និង Gmail ។ | 1 លើក | |
| | សម្រួល ប្រមូលផែនការសកម្មភាពបង្ការទប់ស្កាត់ របស់អន្តរក្រសួងស្ថាប័ន ដែលដឹកនាំ ដោយក្រសួងអប់រំ យុវជន និងកីឡា ។ | 1 លើក | ក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់ |
| | បានពិនិត្យ និងតាមដានព័ត៌មានជាប្រចាំពីសកម្មភាពការបើកវេទិកាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាល លើការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមបណ្តារាជធានី-ខេត្ត តាមរយៈ Telegram ។ | 1 លើក | |

| | | | |
|---|---|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | បានចូលរួមប្រជុំពិភាក្សាពង្រាងផែនការសកម្មភាពរបស់ក្រុមការងារការពារជនរងគ្រោះ សម្រាប់ឆ្នាំ២០១៦ ។ | 1 លើក | ក្រុមជំនួយកិច្ចការអនុវត្តន៍ច្បាប់ |
| | បានធ្វើផែនការសកម្មភាពសម្រាប់ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ ។ និងបានរៀបចំធ្វើរបាយការណ៍ ចងក្រងជាសៀវភៅ ដែលក្រុមការងារជំនួយកិច្ចការការពារជនរងគ្រោះ ។ | 1 លើក | |
| | បានចុះបណ្តុះបណ្តាល ផ្សព្វផ្សាយតាមបណ្តាខេត្ត និងផែនការអនុវត្តបន្ត និង បានធ្វើការតាមដានចំនួនពលករ ដែលបញ្ជូនមកពីប្រទេសក្រៅ ។ | 1 លើក | |
| | បានធ្វើការទំនាក់ទំនងការងារពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្ស ជាមួយខេត្តកោះកុង ព្រះសីហនុ កំពង់ឆ្នាំង និងខេត្ត ពោធិសាត់ ។ | 1 លើក | ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ |
| | កំពុងកសាងផែនការសម្រាប់ត្រីមាសទី១ ឆ្នាំ២០១៦ និង ព្រាងកសាងផែនការហិរញ្ញវត្ថុ ក្នុងការបណ្តុះបណ្តាល មួយវគ្គដែលមានសិក្ខាកាមចូលរួមចំនួន៤០នាក់ ។ និងបានព្រាងកសាងផែនការសម្រាប់បណ្តុះបណ្តាលដល់៤ខេត្ត ។ | 1 លើក | ក្រុមជំនួយកិច្ចការយុត្តិធម៌ |
| | ឯកសារសម្រាប់បណ្តុះបណ្តាល ស្តីពី "ការសម្របសម្រួលការងាររបស់មន្ត្រីនគរបាលការពារព្រំដែន" ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ នៅស្រុកកំរៀង ខេត្តបាត់ដំបង ។ | 1 លើក | |
| | បានចុះបេសកកម្មទៅខេត្តព្រះសីហនុដើម្បីចូលរួមពិនិត្យកែសម្របសម្រួលសេចក្តីព្រាងច្បាប់ "យុត្តិធម៌អនីតិជន" ដែលរៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ។ | 1 លើក | |
| | បេសកកម្មនៅខេត្តបាត់ដំបង ដើម្បីសម្របសម្រួលកិច្ចប្រជុំតាមដានការងាររបស់មន្ត្រីនគរបាលការពារ ព្រំដែន ។ | 1 លើក | ក្រុមជំនួយកិច្ចការយុត្តិធម៌ |

| | | | |
|---|---|---|---|
| | បានចូលរួមធ្វើជាគ្រូបង្គោលបណ្តុះបណ្តាលកងកម្លាំងនគរបាល វរៈសេនាតូចការពារព្រំដែនគោក ស្តីពី ការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស ទេសន្តប្រវេសន៍ការងារ ការរត់ពន្ធមនុស្ស ឬរត់ពន្ធទេសន្តរប្រ វេសន៍ យន្តការជាតិ-រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់ គ.ជ.ប.ជ តាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់ ក្រោមជាតិ នៅទីបញ្ជាការដ្ឋាន នគរបាលជាតិប្រចាំទិសភូមិភាគ៤ កន្ទួត ខេត្តព្រះវិហារ ។ | 1 លើក | ក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិ |
| | បានធ្វើទំនាក់ទំនងជាមួយលោក ឆាយ កុសល មន្ត្រីកុងស៊ុលកម្ពុជាប្រចាំ ប្រទេសម៉ាឡេស៊ី ដើម្បីជួយ អន្តរាគមន៍បញ្ជូនឈ្មោះ ស៊ាម សុខណៃម ភេទស្រី ត្រឡប់មកកម្ពុជាវិញ ដោយទំនាក់ទំនងជាមួយនិយោជក របស់នាងផ្ទាល់ តាមអាស័យដ្ឋាន និងលេខទូរស័ព្ទរបស់ដើមបណ្តឹង បានប្រគល់ឲ្យ (ធ្វើតាមទម្លាប់ មុនៗព្រោះ ធាប់មានប្រសិទ្ធភាព) ជាលទ្ធផល មន្ត្រីកុងស៊ុលថ្មីបានឲ្យដឹង ថាលោក ឆាយ កុសល ត្រូវបានចប់អណត្តិ ហើយវិលត្រឡប់ទៅធ្វើការនៅក្រសួងការបរទេស អស់រយៈ ពេលជាង២ខែ ហើយតែបើយើងចង់ អន្តរាគមន៍ជួយ អ្នកណាម្នាក់ ក៏អាចរកលោកកុសលនៅស្រុកខ្មែរឲ្យជួយបានដែរ ។ | 1 លើក | ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ |
| | ការចង្អុលបង្ហាញពី ឯកឧត្តមអគ្គលេខាធិការ និងកិច្ចអន្តរាគមន៍ ឈ្មោះ វិច្ឆិកា ប្អូនស្រីរបស់ សឿន រដ្ឋា បានសន្យាថា ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៦ ថៅកែម៉ាឡេស៊ីនឹង បញ្ជូន ស៊ាម សុខណៃម ត្រឡប់មកកម្ពុជា វិញតាមសំណូមពររបស់យើង ព្រមទាំងបានបញ្ជូនសំបុត្រយន្តហោះនិងឯកសារពាក់ព័ន្ធមួយចំនួនមកមុនទៀតផង។ | 1 លើក | |
| | បានធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារប្រចាំឆ្នាំ២០១៥ និង ទិសដៅអនុវត្តបន្តនៅឆ្នាំ២០១៦ របស់ក្រុម ការងារទេសន្តរប្រវេសន៍ ។ | 1 លើក | |

| | | | |
|---|---|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ប្រមូលព័ត៌មានតាមរយៈ Telegram គេហទំព័រ និងសារព័ត៌ មានផ្សេងៗ មានអ្នកទោសខ្មែរ ២ នាក់ត្រូវអាជ្ញាធរថៃប្រគល់ខ្លួនឲ្យអាជ្ញាធរកម្ពុជាវិញ នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៦ តាមច្រកទ្វារ អន្តរជាតិជាំស្រងាំ ក្រោយចាប់ខ្លួនបាននៅពេលចូលកាប់ឈើខុសច្បាប់កាលពី ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៤ ។ | 1 លើក | ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ |
| | បានទំនាក់ទំនងទៅលោក ឧត្តមសេនីយ៍ត្រី សៅ ម៉ាឡៃ អនុប្រធាន នាយកដ្ឋានការពារព្រំដែនគោក សុំឲ្យធ្វើលិខិតតាមបែបបទរដ្ឋបាលស្នើសុំគ្រូបង្គោលរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ២ រូបទៅបណ្តុះ បណ្តាលកងកម្លាំងវរៈសេនាតូចការពារព្រំដែនគោក នៅទីបញ្ជាការនគរ បាលប្រចាំទិសភូមិភាគ៤ នៅកន្ទួត ខេត្តព្រះវិហារ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ រយៈពេល ០១ថ្ងៃ ជាលទ្ធផលលោកបានធ្វើតាមការណែនាំរបស់យើងភ្លាមៗ ។ | 1 លើក | |
| | បានចូលរួមប្រជុំផ្ទៀងផ្ទាត់តួលេខខុសគ្នាក្នុងរបាយការណ៍ស្តីពីលទ្ធផល ការងារប្រចាំឆ្នាំ២០១៥ ពាក់ព័ន្ធទេសន្តរ ប្រវេសន៍ការងារ នៅក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ ។ | 1 លើក | |
| | បានចូលរួមកិច្ចប្រជុំគណៈកម្មាការប្រឹក្សាគម្រោង ស្តីពីដំណើរការចាប់ផ្តើមធ្វើគម្រោង ILO-TRIANGLE ដំហ៊ានទី២ ក្រោមការរៀបចំឡើងដោយក្រសួងការងារ និងណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការ ILO នៅ សណ្ឋាគារភ្នំពេញ ។ | 1 លើក | |
| | បានបូកសរុបប្រចាំថ្ងៃនូវចំនួនពលករចំណាកស្រុកខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមកកម្ពុជាវិញ (ពីថ្ងៃ ទី ០១-១៩ ខែមករា ឆ្នាំ២០១៦) ៖<br>• បានចូលរួមស្រង់ស្ថិតិប្រជាពលរដ្ឋធ្វើទេសន្តរប្រវេសន៍ តាមច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មានចំនួន ២.២២៧នាក់ (ស្រី ៧៨៧នាក់ កុមារ ១៩៥នាក់)<br>• បានចូលរួមស្រង់ស្ថិតិប្រជាពលរដ្ឋធ្វើទេសន្តរប្រវេសន៍ តាមច្រកសំពៅលូន ខេត្តបាត់ដំបង មានចំនួន៦៤ នាក់ (ស្រី ២៣នាក់ កុមារ ១១នាក់) ។ | 1 លើក | |

30 លើក